ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៣៩៩ សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការរៀបចំ និង ការប្រព្រឹត្តិទៅ នៃនាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និង អាស៊ាន

## ឧបនាយករដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៤ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការចាត់តាំងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/៩៤/០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤/អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ. បក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨/អនក្រ/បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ និង អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និង កែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ



ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

- បានឃើញអនុក្រឹត្យលេខ ១៣៨/អនក្រ/បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និង រដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១ :**

នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និង អាស៊ាន ជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង មានបេសកកម្ម ដូចខាងក្រោមនេះ :

- រួមចំណែករៀបចំយុទ្ធសាស្ត្រសម្រាប់ចូលរួមការចរចាលើការបង្កើតតំបន់ពាណិជ្ជកម្មសេរី និង រៀបចំយន្តការសម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃកិច្ចព្រមព្រៀងទាំងនោះ
- សម្របសម្រួល និង តាមដានយុទ្ធសាស្ត្រពាក់ព័ន្ធដល់កិច្ចសហប្រតិបត្តិការក្នុងវិស័យហិរញ្ញវត្ថុក្នុងតំបន់ និង ពិភពលោក
- ស្វែងយល់ និង ចូលរួមចំណែកក្នុងការរៀបចំគោលនយោបាយពាណិជ្ជកម្ម និង ហិរញ្ញវត្ថុក្រៅប្រទេស ដោយផ្អែកលើបទពិសោធន៍នៃប្រទេសដែលមានទីផ្សារធំៗ ក្នុងគោលបំណងជំរុញ និង អភិវឌ្ឍទីផ្សារនាំចេញ
- សិក្សា និង ផ្តួចផ្តើមគំនិតអភិវឌ្ឍផលិតផលថ្មី ដើម្បីបង្កើនមុខទំនិញនាំចេញ និង ធ្វើការវិភាគលើភាពខ្លាំង ភាពខ្សោយ កាលានុវត្តភាព និង ការគំរាមកំហែងលើផលិតផលនីមួយៗ
- តាមដានអំពីការអនុវត្តកាតព្វកិច្ចរបស់កម្ពុជា ចំពោះអង្គការពាណិជ្ជកម្មពិភពលោក និង តាមដានការវិវត្តនៃសហប្រតិបត្តិការថ្នាក់តំបន់
- ពិនិត្យ និង ផ្តល់អនុសាសន៍អំពីការគ្រប់គ្រងមូលនិធិនានារបស់អាស៊ាន។

**ប្រការ ២ :**

នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និង អាស៊ាន ដឹកនាំដោយប្រធានមួយរូប និង អនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ។ រចនាសម្ព័ន្ធនាយកដ្ឋានមានចែងនៅក្នុងឧបសម្ព័ន្ធ "ក" និង ការកំណត់ភារកិច្ចតាមក្របខ័ណ្ឌការងារ ជូនថ្នាក់ដឹកនាំនាយកដ្ឋានមានចែងលំអិតនៅក្នុងឧបសម្ព័ន្ធ "ខ"។

**ប្រការ ៣ :**

កែសម្រួលរចនាសម្ព័ន្ធនៃនាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និង អាស៊ានដែលមានការិយាល័យ

ចំណុះដូចខាងក្រោម :

១. ការិយាល័យ តំបន់ពាណិជ្ជកម្មសេរី

២. ការិយាល័យ សហប្រតិបត្តិការហិរញ្ញវត្ថុ

៣. ការិយាល័យ រដ្ឋបាល និង ទំនាក់ទំនងសាធារណៈ

៤. ការិយាល័យ ស្រាវជ្រាវទីផ្សារ

៥. ការិយាល័យ សហប្រតិបត្តិការពហុភាគី និង អនុតំបន់

៦. ការិយាល័យ សិក្សាសម្រួលការនាំចេញ ។

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និង អនុប្រធានមួយចំនួនតាមការចាំបាច់ ។

**ប្រការ ៤ :**

**ការិយាល័យ តំបន់ពាណិជ្ជកម្មសេរី** មានភារកិច្ចដូចតទៅ :

- ជាលេខាធិការដ្ឋានឱ្យអង្គភាពជាតិនៃតំបន់ពាណិជ្ជកម្មសេរី
- ជាចំណុចកណ្ដាលសម្រាប់ការអនុវត្តកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរី ដែលគ្របដណ្ដប់ពាណិជ្ជកម្មទំនិញ ពាណិជ្ជកម្មសេវា និង ការវិនិយោគ
- រួមចំណែកផ្ដួចផ្ដើមគំនិតក្នុងការរៀបចំគោលនយោបាយពាណិជ្ជកម្មក្រៅប្រទេស ដែលពាក់ព័ន្ធដល់ការបង្កើតតំបន់ពាណិជ្ជកម្មសេរី
- សម្របសម្រួលជាមួយស្ថាប័ន និង អង្គភាពពាក់ព័ន្ធចំពោះការសម្រួលពាណិជ្ជកម្ម វិធានការអនាម័យ ភូតគាមអនាម័យ របាំងមិនមែនពន្ធ និង វិធានការមិនមែនពន្ធ ស្តង់ដារ និង ការវាយតម្លៃភាពអនុលោម
- ចូលរួមចរចា និង រួមចំណែកទទួលខុសត្រូវលើផ្នែកជាបន្ទុកទទួលខុសត្រូវរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លើការបង្កើតតំបន់ពាណិជ្ជកម្មសេរី ជាអាទិ៍ មានការសិក្សា និង ការរៀបចំកម្មវិធីកាត់បន្ថយ/លុបពន្ធនាំចូល និង វិធានដើមកំណើតទំនិញដែលសមស្របសម្រាប់ស្ថានភាពផលិតកម្មនៅកម្ពុជា
- រៀបចំឯកសារនានា និង សុំការណែនាំ ឬការសម្រេចពីថ្នាក់ដឹកនាំក្រសួង មុនការចូលរួមប្រជុំក្រុមប្រឹក្សាតំបន់ពាណិជ្ជកម្មសេរីអាស៊ាន (ASEAN Free Trade Area - AFTA)
- រៀបចំយន្តការសមស្របសម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវកាតព្វកិច្ចនានានៃកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរី
- ជួយថ្នាក់ដឹកនាំក្រសួងក្នុងការតាមដានកាតព្វកិច្ចនានារបស់កម្ពុជាក្រោមសហគមន៍សេដ្ឋកិច្ចអាស៊ាន

- សម្របសម្រួលជាមួយស្ថាប័ន និង អង្គភាពពាក់ព័ន្ធ ក្នុងការរៀបចំសំណើគម្រោងនានាក្នុងក្របខ័ណ្ឌសហប្រតិបត្តិការសេដ្ឋកិច្ចក្រោមកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរី
- សហការ ស្វែងយល់ និង សិក្សាកង្វល់នានារបស់វិស័យឯកជនចំពោះការសម្រួល និង ការជំរុញសហប្រតិបត្តិការ និង សមាហរណកម្មសេដ្ឋកិច្ចរវាងកម្ពុជា និង ប្រទេសសមាជិកអាស៊ាន និងដៃគូរបស់អាស៊ាន និង ស្នើដំណោះស្រាយចំពោះឧបសគ្គទាំងនោះ ដែលវិស័យឯកជនអាចជួបប្រទះក្នុងការប្រកបអាជីវកម្មរបស់ខ្លួន
- បង្កើតយន្តការសមស្របដើម្បីជំរុញបណ្តាញទំនាក់ទំនង និង សហប្រតិបត្តិការរវាងវិស័យឯកជនកម្ពុជា និង វិស័យឯកជននៃប្រទេសសមាជិកអាស៊ាន និង ដៃគូរបស់អាស៊ានដើម្បីបង្កើនការនាំចេញរបស់កម្ពុជា
- សិក្សាដោយសហការជាមួយស្ថាប័ន និងអង្គភាពពាក់ព័ន្ធ នូវលទ្ធភាពនៃការអនុម័តវិធានដោយឡែកសម្រាប់ផលិតផលនីមួយៗ (Product Specific Rules - PSR) ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យនៃការកែច្នៃជាដុំកំភួន ដើម្បីបំពេញបន្ថែមឱ្យវិធានទូទៅ ដែលកម្ពុជាពុំអាចសម្រេចបាន
- ស្រាវជ្រាវ និង រិះរកវិធានការសមស្របនានា ដោយសហការជាមួយស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដើម្បីបង្ការ និង ទប់ស្កាត់ការប្រើប្រាស់វិធានដើមកំណើត ដើម្បីបញ្ចៀសការបង់ពន្ធនាំចូល
- លើកអនុសាសន៍ជូនថ្នាក់ដឹកនាំក្រសួង ដើម្បីដោះស្រាយរាល់បញ្ហា ឧបសគ្គ និង វិវាទនានា ដែលអាចកើតមានឡើងក្នុងការអនុវត្តកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរី
- រៀបចំចងក្រង និង រក្សាទុកឯកសារនានាពាក់ព័ន្ធដល់តំបន់ពាណិជ្ជកម្មសេរី
- រៀបចំសិក្ខាសាលា និង វគ្គបណ្តុះបណ្តាលថ្នាក់ជាតិ និង តំបន់ ដើម្បីផ្សព្វផ្សាយកាតព្វកិច្ចដែលត្រូវបំពេញក្រោមកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរី
- តាមដាន និង លើកយោបល់ ឬអនុសាសន៍ ចំពោះការប្រែប្រួលទាំងឡាយរបស់តំបន់ពាណិជ្ជកម្មសេរីនានា ក្រៅពីតំបន់ពាណិជ្ជកម្មសេរីជាមួយអាស៊ានដែលអាចមានឥទ្ធិពលដល់ការធ្វើពាណិជ្ជកម្មរបស់កម្ពុជា និង អាស៊ាន។

ប្រការ ៥ :

**ការិយាល័យ សហប្រតិបត្តិការហិរញ្ញវត្ថុ** មានភារកិច្ចដូចតទៅ :

- សម្របសម្រួល តាមដានគោលនយោបាយ និង យុទ្ធសាស្ត្រពាក់ព័ន្ធដល់កិច្ចសហប្រតិបត្តិការក្នុងវិស័យសេវាហិរញ្ញវត្ថុ
- បំពេញតួនាទីជាការិយាល័យសម្របសម្រួលជាមួយការិយាល័យជំនាញនៃនាយកដ្ឋាន

ពាក់ព័ន្ធ ក្នុងការរៀបចំអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលលើកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យសេវាហិរញ្ញវត្ថុក្នុងតំបន់ និង អន្តរជាតិ

- តាមដានសហប្រតិបត្តិការលើវិស័យហិរញ្ញវត្ថុ ធនាគារ ធានារ៉ាប់រង និង ទីផ្សារទុន ដែលបម្រើគោលដៅនៃការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជានៅក្នុងតំបន់ និង ពិភពលោក
- សហការជាមួយការិយាល័យពាក់ព័ន្ធដើម្បីស្រាវជ្រាវ ចងក្រង និង ផ្សព្វផ្សាយសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀង អនុស្សារណៈ និង ឯកសារនានាក្នុងវិស័យសេវាហិរញ្ញវត្ថុដែលពាក់ព័ន្ធទៅនឹងការធ្វើសមាហរណកម្មសេដ្ឋកិច្ចនៅក្នុងតំបន់ និង ពិភពលោក។

**ប្រការ ៦ :**

**ការិយាល័យ រដ្ឋបាល និង ទំនាក់ទំនងសាធារណៈ** មានភារកិច្ចដូចតទៅ :

- ផ្តល់ព័ត៌មាន ឬណែនាំសហគមន៍ពាណិជ្ជកម្មអំពីអត្ថប្រយោជន៍នៃការអនុវត្តកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរី និង រាល់ព័ត៌មានផ្សេងទៀតដែលស្ថិតនៅក្នុងការទទួលខុសត្រូវរបស់នាយកដ្ឋាន
- គ្រប់គ្រងរាល់លិខិតចេញ-ចូលរបស់នាយកដ្ឋាន
- កត់ត្រា និង រក្សាទុកឯកសាររបស់នាយកដ្ឋាន
- រៀបចំសុំគោលការណ៍ និង គម្រោងចំណាយនៃបេសកកម្មរបស់ថ្នាក់ដឹកនាំ និង មន្ត្រីទាំងអស់នៃនាយកដ្ឋាន និង សំណើសុំទូទាត់ចំណាយទាំងនោះ នៅពេលចប់បេសកកម្ម
- រៀបចំគម្រោងស្នើសុំសម្ភារៈការិយាល័យដែលជាសេចក្តីត្រូវការរបស់នាយកដ្ឋាន
- ថែរក្សាទ្រព្យសម្បត្តិរដ្ឋដែលបានផ្តល់ជូននាយកដ្ឋាន ព្រមទាំងរៀបចំសន្និធិសម្ភារៈទាំងនោះរៀងរាល់ឆ្នាំ
- ពិនិត្យ និង ផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្រសួងលើគម្រោងចំណាយរៀបចំកិច្ចប្រជុំ សម្រាប់ការងារអាស៊ានរបស់ក្រសួង និង ស្ថាប័ននានា តាមការប្រគល់ភារកិច្ច
- ពិនិត្យ និង ផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្រសួងលើគម្រោងចំណាយបេសកកម្មក្នុង និង ក្រៅប្រទេស សម្រាប់ការងារអាស៊ានរបស់ក្រសួង និង ស្ថាប័ននានា
- ពិនិត្យ និង ផ្តល់អនុសាសន៍ដល់គម្រោងចំណាយរបស់លេខាធិការដ្ឋានអាស៊ាន និង មូលនិធិអាស៊ានផ្សេងៗ ដើម្បីសុំការសម្រេចពីថ្នាក់ដឹកនាំក្រសួង
- ចូលរួមប្រជុំគណៈកម្មាធិការថវិការបស់អាស៊ាន និង កិច្ចប្រជុំផ្សេងទៀតពាក់ព័ន្ធដល់ការគ្រប់គ្រងមូលនិធិនានារបស់អាស៊ាន

- រៀបចំគម្រោងចំណាយកិច្ចប្រជុំ និង សិក្ខាសាលានានាពាក់ព័ន្ធដល់អាស៊ាន ដែលនាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និង អាស៊ានធ្វើជាម្ចាស់ផ្ទះ និង តាមការសម្រេចរបស់ថ្នាក់ដឹកនាំក្រសួង គម្រោងចំណាយផ្សេងទៀត ដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុធ្វើជាម្ចាស់ផ្ទះ។

**ប្រការ ៧ :**

**ការិយាល័យ ស្រាវជ្រាវទីផ្សារ** មានភារកិច្ចដូចតទៅ :

- ស្រាវជ្រាវប្រពៃណី និង ទំនៀមទម្លាប់របស់ទីផ្សារអំពីការប្រើប្រាស់ផលិតផល ដែលជាមុខសញ្ញានៃការនាំចេញនាពេលបច្ចុប្បន្ន និង ទីផ្សារទៅអនាគត
- ប្រមូលផ្តុំព័ត៌មានពាក់ព័ន្ធដល់ស្តង់ដាររស់នៅ រចនាសម្ព័ន្ធនៃស្ថាប័ន និង អង្គភាពទទួលខុសត្រូវពាណិជ្ជកម្មក្នុង និង ក្រៅប្រទេសរបស់ប្រទេសនាំចូល
- សិក្សាពីប្រព័ន្ធបែងចែកទំនិញក្នុងទីផ្សារ ដែលជាមុខសញ្ញានៃការនាំចេញ និង អំពីក្រុមហ៊ុនពាណិជ្ជកម្មរដ្ឋផងដែរ បើប្រទេសនាំចូលមានក្រុមហ៊ុនរដ្ឋ
- សិក្សារបបពាណិជ្ជកម្មក្នុងប្រទេស ក្រៅប្រទេស និង ពាណិជ្ជកម្មផ្តាច់មុខ ជាជំហានដំបូងទីផ្សារដែលជាទិសដៅនៃការនាំចេញបច្ចុប្បន្ន និង ទីផ្សារផ្សេងទៀត ដែលជាទិសដៅនាំចេញទៅអនាគត
- សិក្សាអត្រាពន្ធនាំចេញ នាំចូល កូតាអត្រាពន្ធ អត្រាពន្ធក្នុងស្រុក ព្រមទាំងច្បាប់ វិធាន និង បទបញ្ញាពាក់ព័ន្ធដល់ការអនុវត្តច្បាប់ទាំងនេះ
- ប្រមូលផ្តុំ និង សិក្សាច្បាប់ វិធាន និង បទបញ្ញាស្តីពីអនាម័យ ភូតគាមអនាម័យ របាំងបច្ចេកទេសពាណិជ្ជកម្ម និង វិធានការមិនមែនពន្ធរបស់ទីផ្សារ ព្រមទាំងតាមដានជាប់ជាប្រចាំនូវការប្រែប្រួលនានារបស់វាដែលអាចមានឥទ្ធិពលដល់ការនាំចេញរបស់កម្ពុជា
- ប្រមូលផ្តុំ និង សិក្សាប្រព័ន្ធអនុគ្រោះដែលប្រទេសសមាជិកអង្គការពាណិជ្ជកម្មពិភពលោកផ្តល់ជូនប្រទេសក្រីក្រ និង ប្រទេសកំពុងអភិវឌ្ឍ ជាពិសេសផ្តោតទៅលើបញ្ជីទំនិញ និង វិធានដើមកំណើតទំនិញ ក្នុងទិសដៅសុំធ្វើការកែប្រែ ឬកែសម្រួលក្នុងករណីកម្ពុជាពុំអាចទាញយកប្រយោជន៍បានច្រើនពីប្រព័ន្ធនេះ
- ចូលរួមចំណែកក្នុងការរៀបចំគោលនយោបាយពាណិជ្ជកម្មក្រៅប្រទេស ដោយផ្អែកលើបទពិសោធន៍នៃការសិក្សារបបពាណិជ្ជកម្មនៃប្រទេសនានា ដែលបានទទួលជោគជ័យក្នុងការធ្វើពាណិជ្ជកម្ម
- ស្វែងយល់ពីរបបវិនិយោគកម្ពុជា និង ដៃគូសំខាន់ៗ ក្នុងទិសដៅទាក់ទាញវិនិយោគមកកម្ពុជា

- សិក្សា និង ស្វែងយល់ពីការសម្រួលពាណិជ្ជកម្មនៅទីផ្សារនានា ដែលជាទិសដៅនៃការនាំចេញ
- សិក្សាលទ្ធភាពនៃការអភិវឌ្ឍទីផ្សារថ្មីសម្រាប់ផលិតផលដែលបាន និង កំពុងនាំចេញ និង សម្រាប់ផលិតផលថ្មី
- សហការជាមួយស្ថានបេសកកម្មកម្ពុជានៅក្រៅប្រទេស ដើម្បីជួយស្វែងរកព័ត៌មាន ឯកសារចាំបាច់បម្រើដល់ការនាំចេញផលិតផលកម្ពុជា
- តាមដានផលិតកម្មសកលលោក និង នៅប្រទេសនាំចូលនៃផលិតផលដូចគ្នានឹងផលិតផលដែលកម្ពុជាកំពុងនាំចេញ
- រក្សាទំនាក់ទំនងជិតស្និទ្ធជាមួយមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ ដើម្បីទទួលបានព័ត៌មានពាណិជ្ជកម្ម និង ផលិតកម្មតាមមុខទំនិញនីមួយៗ។

ប្រការ ៨ :

**ការិយាល័យ សហប្រតិបត្តិការពហុភាគី និង អនុតំបន់** មានភារកិច្ចដូចតទៅ :

- រួមចំណែកក្នុងការរៀបចំនយោបាយពាណិជ្ជកម្មអន្តរជាតិ ពាក់ព័ន្ធដល់អង្គការពាណិជកម្មពិភពលោក
- តាមដាន និង ផ្តល់អនុសាសន៍ជូនក្រសួងសេដ្ឋកិច្ច និង ហិញ្ញវត្ថុ អំពីការអនុវត្តកាតព្វកិច្ចកម្ពុជាចំពោះអង្គការពាណិជ្ជកម្មពិភពលោក
- សម្របសម្រួលកម្រិតអន្តរនាយកដ្ឋានក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចំពោះការអនុវត្តកាតព្វកិច្ចនានាពាក់ព័ន្ធដល់អង្គការពាណិជកម្មពិភពលោក
- តាមដាន និង ផ្តល់អនុសាសន៍ជូនក្រសួងអំពីសហប្រតិបត្តិការពាណិជ្ជកម្មថ្នាក់អនុតំបន់
- រក្សាទំនាក់ទំនងជិតស្និទ្ធជាមួយនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងពាណិជ្ជកម្ម និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីធានាប្រសិទ្ធភាព និង ការគោរពតាមកាលកំណត់នៃកាតព្វកិច្ចរបស់កម្ពុជាក្រោមអង្គការពាណិជ្ជកម្មពិភពលោក និង អនុតំបន់
- តាមដាន និង លើកយោបល់ជូនក្រសួងអំពីទំនាក់ទំនងជាមួយអង្គការសន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និង ការអភិវឌ្ឍ ( United Nations Conference on Trade and Development Economic - UNCTAD) និង គណៈកម្មការសេដ្ឋកិច្ច និង សង្គម សម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក (Social Commission for Asia and the Pacific - ESCAP) និង អង្គការតំបន់ផ្សេងទៀតតាមការសម្រេចរបស់រដ្ឋមន្ត្រី
- លើកយោបល់ជូនថ្នាក់ដឹកនាំក្រសួង នៅពេលធ្វើការពិនិត្យឡើងវិញនូវគោលនយោបាយពាណិជ្ជកម្មក្នុងក្របខ័ណ្ឌអង្គការពាណិជកម្មពិភពលោក

- សហការជាមួយការិយាល័យសិក្សាសម្រួលការនាំចេញក្នុងការសិក្សាអំពីប្រព័ន្ធអនុគ្រោះផ្តល់ឱ្យក្នុងក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក និង លើកអនុសាសន៍ចាំបាច់ជូនថ្នាក់ដឹកនាំក្រសួង
- តាមដានការវិវត្តសហប្រតិបត្តិការថ្នាក់តំបន់ដែលកម្ពុជាពុំមែនជាសមាជិក ដើម្បីទទួលបានបទពិសោធន៍ល្អសម្រាប់សហប្រតិបត្តិការអនុតំបន់ដែលកម្ពុជាជាសមាជិក។

**ប្រការ ៩ :**

**ការិយាល័យ សិក្សាសម្រួលការនាំចេញ** មានភារកិច្ចដូចតទៅ :

- ពន្យល់ផលិតករកម្ពុជាអំពីការទាមទារលើគុណភាព អនាម័យ ភូតគាមអនាម័យ ចំពោះផលិតផលនាំចេញ ទៅតាមទិសដៅនាំចេញនីមួយៗ
- រក្សាទំនាក់ទំនងជិតស្និទ្ធជាមួយអ្នកនាំចេញកម្ពុជា ដើម្បីស្វែងយល់ពីឧបសគ្គនានាដែលបាន និង កំពុងកើតមានឡើងនៅទីផ្សារនាំចេញ
- សហការជាមួយស្ថាប័ន និង អង្គភាពពាក់ព័ន្ធនៃប្រទេសនាំចូល ដើម្បីជួយដោះស្រាយរាល់ឧបសគ្គនានាដែលបានកើតមានឡើង
- តាមដានជាប់ជាប្រចាំ ការនាំចូលផលិតផលដូចគ្នានឹងផលិតផលដែលអាចផលិតក្នុងស្រុក ក្នុងទិសដៅការពារផលិតករកម្ពុជាប្រឆាំងនឹងការលក់បង្ខូចថ្លៃដើម្បីផ្តលគួប្រជែង
- ផ្អែកលើព័ត៌មានពីការិយាល័យសិក្សាទីផ្សារ ផ្តួចផ្តើមគំនិតអភិវឌ្ឍផលិតផលថ្មី ដើម្បីបង្កើនមុខទំនិញនាំចេញ
- តាមដានយ៉ាងជិតស្និទ្ធផលិតផលនាំចេញ ចាប់តាំងពីដំណាក់កាលផលិតរហូតដល់វេចខ្ចប់នាំចេញ ជាពិសេសកសិផល
- ជួយផ្តល់ដល់អ្នកនាំចេញនូវព័ត៌មានពាក់ព័ន្ធដល់នីតិវិធី ឯកសារពាណិជ្ជកម្ម ការកែច្នៃផលិតផល ឱ្យស្របតាមទីផ្សារ ការវេចខ្ចប់សម្រាប់ការនាំចេញ ការដឹកជញ្ជូន ការកំណត់តម្លៃការត្រួតពិនិត្យគុណភាព ហិរញ្ញប្បទានដល់ការនាំចេញ ការផ្សព្វផ្សាយពាណិជ្ជកម្ម និង ច្បាប់ទម្លាប់នៃទីផ្សារនាំចូល
- ស្នើគំនិតរៀបចំឱ្យមានបេសកកម្មរួមខាងផ្នែកពាណិជ្ជកម្មទៅក្រៅប្រទេស ដើម្បីស្វែងយល់ពីបទពិសោធន៍របស់ប្រទេសដែលបានទទួលជោគជ័យក្នុងការជំរុញពាណិជ្ជកម្ម
- ជួយបណ្តុះបណ្តាលសហគមន៍អ្នកនាំចេញអំពីបទពិសោធន៍គោលនយោបាយពាណិជ្ជកម្ម ច្បាប់ វិធាន ទម្លាប់ និង បទបញ្ជានានារបស់កម្ពុជា និង ប្រទេសទិញផលិតផលកម្ពុជា
- តាមដានយុទ្ធសាស្ត្រជំរុញការនាំចេញរបស់រាជរដ្ឋាភិបាល

- រួមចំណែកក្នុងការវិភាគលើភាពខ្លាំង ភាពខ្សោយ កាលានុវត្តភាព និង ការគំរាមកំហែងរបស់ផលិតផលនិមួយៗ។

**ប្រការ ១០ :**

ភារកិច្ចទាំងឡាយណាដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់នាយកដ្ឋាន ឬអង្គភាពជំនាញដទៃ ប្រធាននាយកដ្ឋានត្រូវសហការជាមួយនាយកដ្ឋាន ឬអង្គភាពពាក់ព័ន្ធនោះ សុំគោលការណ៍ពីថ្នាក់ដឹកនាំក្រសួង ដើម្បីរួមគ្នាដោះស្រាយ។

**ប្រការ ១១ :**

ប្រកាស ឬរាល់លិខិតបទដ្ឋានដែលមានពីមុនហើយមានខ្លឹមសារផ្ទុយពីខ្លឹមសារនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១២ :**

អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នាយខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និង អាស៊ាន និង គ្រប់នាយកដ្ឋាន និង អង្គភាពពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្ត និង សហការតាមប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៩

គាត ឈន់

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួង និង ស្ថាប័នពាក់ព័ន្ធ

  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- ដូចប្រការ ១២ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

## ១. ការកំណត់ភារកិច្ចតាមក្រុមចំណុះការងារជូនថ្នាក់នាយកដ្ឋាន

- លោក អ៊ុយ សម្បត្តិ ប្រធាននាយកដ្ឋានដឹកនាំ និង គ្រប់គ្រងការងាររួមទាំងអស់របស់នាយកដ្ឋាន និង ដោយឡែកទទួលបន្ទុកគ្រប់គ្រងការិយាល័យតំបន់ពាណិជ្ជកម្មសេរី និង កិច្ចការដទៃទៀតតាមការប្រគល់ភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួង ។

- លោក លី សែ អនុប្រធានទី ១ នាយកដ្ឋាន ទទួលបន្ទុកការិយាល័យសហប្រតិបត្តិការហិរញ្ញវត្ថុ ។

- លោកស្រី ប៊ុន នារី អនុប្រធាននាយកដ្ឋាន ទទួលបន្ទុកការិយាល័យរដ្ឋបាល និង ទំនាក់ទំនងសាធារណៈ ។

- លោក គង់ វដ្ឋា អនុប្រធាននាយកដ្ឋាន ទទួលបន្ទុកការិយាល័យស្រាវជ្រាវទីផ្សារ ។

- លោក ម៉ី សុជាតិ អនុប្រធាននាយកដ្ឋាន ទទួលបន្ទុកការិយាល័យសហប្រតិបត្តិការពហុភាគី និង អនុតំបន់ ។

- លោក លុប សុធនវិចិត្រ អនុប្រធាននាយកដ្ឋាន ទទួលបន្ទុកការិយាល័យសិក្សាសម្រួលការនាំចេញ ។

- អនុប្រធាននាយកដ្ឋានអាចទទួលភារកិច្ចផ្សេងៗទៀត ក្រៅពីភារកិច្ចដូចមានចែងលំអិតតាមការិយាល័យនីមួយៗ តាមការប្រគល់របស់ប្រធាននាយកដ្ឋាន ។

## ២. នីតិវិធី និង របៀបរបបបំពេញការងារ

- រាល់សំណុំឯកសារដែលត្រូវដាក់សុំការសម្រេចពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវរៀបចំតាមឋានានុក្រមការងារ និង ចុះហត្ថលេខាចុងក្រោយដោយប្រធាននាយកដ្ឋាន ។

- នឹងមានការប្រជុំប្រចាំខែ នៅរៀងរាល់ចុងខែនីមួយ ដើម្បីពិនិត្យតាមដាន និង កំណត់ទិសដៅភារកិច្ចសម្រាប់ខែបន្ទាប់ និង ដោះស្រាយបញ្ហាដែលជាកង្វល់របស់មន្ត្រីទទួលបន្ទុក និង កែលំអចំណុចខ្វះខាត ។

ក្នុងករណីដែលប្រធាននាយកដ្ឋានអវត្តមាន ឬជាប់រវល់បំពេញបេសកកម្មក្រៅប្រទេស ភារកិច្ចដឹកនាំនាយកដ្ឋានត្រូវផ្ទេរទៅឱ្យអនុប្រធាន ដោយប្រធាននាយកដ្ឋាន បន្ទាប់ពីការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ចំពោះកិច្ចការបន្ទាន់នានារបស់ការិយាល័យតំបន់ពាណិជ្ជកម្មសេរី ប្រធានស្តីទីត្រូវពិគ្រោះយោបល់តាមមធ្យោបាយអេឡិចត្រូនិចជាមួយប្រធាននាយកដ្ឋាន មុនលើកសំណើជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និង សម្រេច ។ ប្រធានស្តីទីត្រូវរាយការណ៍ជូនប្រធាននាយកដ្ឋានពីសកម្មភាពការងារនានាដែលបានបំពេញ ក្នុងពេលអវត្តមានប្រធាននាយកដ្ឋាន ។

# រចនាសម្ព័ន្ធ នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និង អាស៊ាន

